**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល ។

## សម្រេច

**មាត្រា១ៈ**

ត្រូវបានកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ដែនជម្រកសត្វព្រៃលំផាត់ លើផ្ទៃដីទំហំ ១.៩៥០ ហិកតា (មួយពាន់ ប្រាំបួនរយ ហាសិបហិកតា) ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្ថិតនៅក្នុងភូមិសាស្ត្រស្រុកលំផាត់ ខេត្តរតនៈគីរី សម្រាប់ផ្តល់ជូនក្រុមហ៊ុន **មុង ពេជ្រ អភិវឌ្ឍន៍កសិ-ឧស្សាហកម្ម** ធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដំណាំកសិ-ឧស្សាហកម្ម និងដំណាំកៅស៊ូ ដែលមានទីតាំង និងនិយាមកា ដូចមានក្នុងផែនទីភ្ជាប់នឹងលិខិតលេខ ២៣៤ សជណ ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ២០១១ ជាឧបសម្ព័ន្ធ។

**មាត្រា២៖**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣៖**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តរតនៈគីរី ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*__កន្លែងទទួល:__*

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
  "__ដើម្បីគោរពជូនជ្រាប__"
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ

## ផែនទី ទីតាំងដីស្នើសុំវិនិយោគអភិវឌ្ឍន៍ របស់ក្រុមហ៊ុន ម្លូដពេជ្រ អភិវឌ្ឍន៍ កសិ-ឧស្សាហកម្ម ស្ថិតនៅក្នុងឃុំកាឡែង ស្រុកលំផាត់ ខេត្តរតនៈគិរី នៃដែនជម្រកសត្វព្រៃលំផាត់ លើផ្ទៃដីចំនួន ១.៩៥០ ហិកតា




ផែនទី និងនិយាមការនេះ ជាឯកសារ
ភ្ជាប់នឹងលិខិតលេខ ...១៤៩.គ.៣...
ចុះថ្ងៃទី ...២៥... ខែ ...កុម្ភៈ... ឆ្នាំ ២០១១..
ទ. ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

ផែនទី និងនិយាមការនេះ ជាឯកសារ
ភ្ជាប់នឹងលិខិតលេខ ...៤៣៤... សជណ
ចុះថ្ងៃទី ......០២ ខែ ...មីនា...... ឆ្នាំ ២០១១...
ឧ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
ម៉ៅ ហាស់

សញ្ញាសម្គាល់
- ភូមិ
- ចំណុចនិយាមកា
- ទីតាំងដីវិនិយោគ
- ផ្លូវគ្រួសក្រហម
- ផ្លូវលំ
- អូរ ព្រែក ទន្លេ
- ព្រំប្រទល់តំបនការពារធម្មជាតិ

| Id | Lp | Coor_X | Coor_Y |
|---|---|---|---|
| 1 | A | 727034 | 1491793 |
| 2 | B | 727037 | 1483099 |
| 3 | C | 722046 | 1483086 |
| 4 | D | 722048 | 1483954 |
| 5 | E | 723995 | 1483967 |
| 6 | F | 724009 | 1487038 |
| 7 | G | 726305 | 1487089 |
| 8 | H | 726350 | 1490383 |
| 9 | I | 724009 | 1490393 |
| 10 | J | 724035 | 1491443 |